# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៨៤២ ព្ររ.៣.១-៩៧

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**លោកព្រះរាជអាជ្ញាអមតុលាការខេត្តបន្ទាយមានជ័យ**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** អំពីការបាញ់សម្លាប់កូនខ្មែរជាអនីតិជននៅព្រំប្រទល់ដែនថៃនពីសំណាក់កងតម្រួតថៃ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៩៧ បណ្តាលឱ្យស្លាប់៣នាក់ របួស១នាក់ និងរត់រួច ១នាក់។

**<u>យោង:</u>** លិខិតលេខ ១៧-២-៩៧ របស់ការិយាល័យមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ។

លិខិតលេខ ១៤-៩៧ ចុះថ្ងៃទី២៦-០៤-៩៧ របស់ការិយាល័យកណ្តាលនគរបាលយុត្តិធម៌ ខេត្តបន្ទាយមានជ័យ ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងបានទទួលលិខិតដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ស្តីពីកងតម្រួតថៃបាញ់សម្លាប់កូនខ្មែរជាអនីតិជនចូលលួចនៅតំបន់កសិដ្ឋានថៃ កាលពីថ្ងៃទី០៣-០១-៩៧ បណ្តាលឱ្យស្លាប់៣នាក់ របួស១នាក់ និងរត់រួច១នាក់ ។

ក្នុងករណីនេះសូមលោកបញ្ជាទៅនគរបាលយុត្តិធម៌ខេត្តបន្ទាយមានជ័យឱ្យរាយការណ៍និងបញ្ជូនសំនុំរឿងក្តីនេះមកអយ្យការជាបន្ទាន់ ហើយនៅពេលដែលស្នងការនគរបាលរាយការណ៍ មកដល់អយ្យការភ្លាមលោកព្រះរាជអាជ្ញាត្រូវចាត់អោយនគរបាលធ្វើការស៊ើបអង្កេតរឿងនេះអោយជាប់ ។

ម៉្យាងទៀតកាលណាមានរឿងអ្វីកើតឡើងដែលពាក់ពន្ធ័នឹងរបៀបរៀបរយសាធារណៈ និងសិទ្ធរបស់មនុស្សជាពិសេសប៉ះពាល់ដល់ផលប្រយោជន៍ អនីតិជនខ្មែរដែលត្រូវរងគ្រោះ ដោយអំពើរំលោភបំពានពីអាជ្ញាធរមានសមត្ថកិច្ចឬជនបរទេសព្រះរាជអាជ្ញាត្រូវរាយការណ៍មកក្រសួងជាបន្ទាន់ ដើម្បីក្រសួងជួយផ្តល់ជាយោបល់សម្រាប់ចាត់ការដោះស្រាយរឿងនោះឱ្យ បានឆាប់និងត្រឹមត្រូវតាមច្បាប់ ។

សូមលោកព្រះរាជអាជ្ញាចាត់ការតាមការណែនាំនេះឱ្យបានឆាប់ជាទីបំផុត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-អយ្យការគ្រប់ខេត្ត-ក្រុង
-ជ្រាបនិងចាត់ការតាមការណែនាំនេះ